លេខ ៥៦ ចេញផ្សាយថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦

# ព្រឹត្តិបត្រព័ត៌មាន

## ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦

## មាតិកា


- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍ វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"................................ ទំព័រទី ១
- វេទិកាសាធារណៈ ស្តីពី "ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាឆ្នាំ ២០២៦"........................................................................ ទំព័រទី ២
- វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិនិងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៨....................................... ទំព័រទី ២
- កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤........................................ ទំព័រទី ២
- កម្មវិធីសិក្ខាសាលាស្តីពី "បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា"................ ទំព័រទី ៣
- វេទិកាស្តីពីពន្ធដារ-Tax Forum................................................... ទំព័រទី ៣
- សិក្ខាសាលាស្តីពី "យន្តការបរធនបាលកិច្ចក្នុងបរិការណ៍នៃការវិវត្តថ្មីៗ". ទំព័រទី ៣
- កម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៨ ឆ្នាំ២០២៦. ទំព័រទី ៤
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី"........................ ទំព័រទី ៤
- ការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) សម្រាប់ចូលបម្រើការងារនៅ ន.ប.ធ.... ទំព័រទី ៥
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី"........................ ទំព័រទី ៥
- សិក្ខាសាលាពិគ្រោះយោបល់ស្តីពី "យុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០"............... ទំព័រទី ៦
- កិច្ចប្រជុំបច្ចេកទេសជាមួយតំណាងដៃគូអភិវឌ្ឍ ពិនិត្យនិងពិភាក្សាលើរបាយការណ៍តាមដាននិងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤.... ទំព័រទី ៦
- សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្តីពី "ការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២".... ទំព័រទី ៧
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម ដល់រដ្ឋបាលខេត្តគោលដៅថ្មី"........................................ ទំព័រទី ៧
- កិច្ចប្រជុំក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ...... ទំព័រទី ៨
- កិច្ចប្រជុំអន្តរក្រសួងស្តីពីការពិនិត្យ និងពិភាក្សាលើ "សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិកីឡាជនពិការ តេជោសែន"............ ទំព័រទី ៨
- កិច្ចប្រជុំអន្តរក្រសួងស្តីពី "ការពិគ្រោះយោបល់ប្រមូលធាតុចូលលើសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍធុរកិច្ចថ្មី ២០២៦-២០៣០"........................................................................ ទំព័រទី ៨
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"................................ ទំព័រទី ៩
- វេទិកាបណ្តាញហិរញ្ញវត្ថុ និងបច្ចេកវិទ្យាសកលជប៉ុន ឆ្នាំ២០២៦........ ទំព័រទី ៩


TRUST REGULATOR

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃសៅរ៍ ១៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យ អង្គរខេមរា បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍ វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណើ សាគល** អគ្គនាយករង នៃនិយ័តករបរធនបាលកិច្ច និង **លោកស្រី ស៊ិន លក្ខិណា នាយិការងប្រតិបត្តិនៃសាកលវិទ្យាល័យអង្គរខេមរា** នៅសាកលវិទ្យាល័យអង្គរខេមរា ទីរួមខេត្តកំពត។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធន-បាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យ អង្គរខេមរា។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## វេទិកាសាធារណៈ ស្តីពី "ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាឆ្នាំ ២០២៦"

នៅព្រឹកថ្ងៃចន្ទ ១៥កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមវេទិកាសាធារណៈ ស្តីពី "ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាឆ្នាំ ២០២៦" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យ ផាន់ ផល្លា និង ឯកឧត្តម ចាន់ សុធី** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញភូគីត្រា។



រូបភាព៖ វេទិកាសាធារណៈ ស្តីពី "ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាឆ្នាំ ២០២៦"។

## វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៨

នាព្រឹកថ្ងៃអង្គារ ១រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញប្រកាសបើក "វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៨" ដែលរៀបចំដោយនិយ័តករបរធនបាលកិច្ច នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំរយៈពេលចំនួន ៣ ថ្ងៃពេញ ចាប់ពីថ្ងៃទី៣-៥ ខែកុម្ភៈ ឆ្នាំ២០២៦និងមានអ្នកចូលរួមសរុបចំនួន ១៤៨ រូប ដែលមានសមាសភាពចូលរួមពីក្រុមហ៊ុននិងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច, បុគ្គលដែលមានបំណងផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច និងសាធារណជន។



រូបភាព៖ វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិនិងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៨។

## កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤

នាព្រឹកថ្ងៃអង្គារ ១ រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក យុន វាសនា** អគ្គនាយករង និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រព័ន្ធអនឡាញ Zoom។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



**រូបភាព៖** កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤។

## កម្មវិធីសិក្ខាសាលាស្តីពី "បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា"

នារសៀលថ្ងៃពុធ ២រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីសិក្ខាសាលាស្តីពី "បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា" ដោយមានការអញ្ជើញចូលរួមធ្វើបាឋកថាដោយ **ឯកឧត្តម អ៊ុំ លុយណា** អគ្គនាយកនៃអគ្គនាយកដ្ឋានគោល-នយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

កម្មវិធីនេះមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ និងលោក លោកស្រីតំណាងឱ្យនិយ័តករទាំងអស់ក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងតំណាងក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងបុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងសិក្ខាកាមនៃកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ក្នុងវិស័យបរធនបាលកិច្ច លើកទី៨ ផងដែរ។



**រូបភាព៖** កម្មវិធីសិក្ខាសាលាស្តីពី "បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា"។

## កម្មវិធី "វេទិកាស្តីពីពន្ធដារ-Tax Forum"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៣ រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច** និងសហការី បានអញ្ជើញចូលរួមកម្មវិធី "វេទិកាស្តីពីពន្ធដារ-Tax Forum" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**។

កម្មវិធីនេះ សហការរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ និងសភាពាណិជ្ជកម្មកម្ពុជា ក្នុងគោលបំណងប្រកាសបើកឱ្យដំណើការប្រព័ន្ធ Tax Home Pay, កិច្ចពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធកាតព្វកិច្ចពន្ធជាមួយវិស័យឯកជនព្រមទាំងលើកកម្ពស់អនុលោមភាពសារពើពន្ធដើម្បីបន្តអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន អង្គភាព តំណាងសភាពាណិជ្ជកម្មកម្ពុជា និងវិស័យឯកជន នៅអគារអគ្គនាយកដ្ឋានពន្ធដារ (GDT Tower)។



**រូបភាព៖** កម្មវិធី "វេទិកាស្តីពីពន្ធដារ-Tax Forum"។

## សិក្ខាសាលាស្តីពី "យន្តការបរធនបាលកិច្ចក្នុងបរិការណ៍នៃការវិវត្តថ្មីៗ"

នារសៀលថ្ងៃព្រហស្បតិ៍ ៣រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាស្តីពី "យន្តការបរធនបាលកិច្ចក្នុងបរិការណ៍នៃការវិវត្តថ្មីៗ" នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។ កិច្ចពិភាក្សានេះ មានការអញ្ជើញចូលរួមដោយវាគ្មិនកិត្តិយសដែលសុទ្ធសឹងជាអ្នកជំនាញក្នុងវិស័យបរធនបាលកិច្ច, វិស័យធនាគារ និងវិស័យវាយតម្លៃអចលនវត្ថុ រួមមាន៖ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច,



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

**បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិធនាគារ អេស៊ីលីដា ភី-អិលស៊ី, ឧកញ៉ា សន សៀប ប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា** និង **លោក ហុង ជៀប ប្រធាននាយកប្រតិបត្តិធនាគារស៊ីអាយអិមប៊ី ភីអិលស៊ី**។ នៅក្នុងកម្មវិធីនេះ វាគ្មិនបានផ្តោតការពិភាក្សាអំពីកំណើនយ៉ាងឆាប់រហ័សរបស់ទីផ្សារបរធនបាលកិច្ច ដែលការណ៍នេះ គឺបានឆ្លុះបញ្ចាំងពីនិន្នាការកើនឡើងនៃការងាកទៅការប្រើប្រាស់យន្តការបរធនបាលកិច្ចនៅក្នុងសកម្មភាពវិនិយោគឯកជន និងសាធារណៈក្នុងវិស័យផ្សេងៗ និងពិភាក្សាអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់យន្តការបរធនបាលកិច្ចដែលជាយន្តការផ្តល់ទំនុកចិត្តខ្ពស់ និងមានយន្តការតាមដាន និងត្រួតពិនិត្យច្បាស់លាស់។ លើសពីនេះ កម្មវិធីនេះក៏បានពិភាក្សាអំពីនិន្នាការនៃកំណើនក្នុងការប្រើប្រាស់ផលិតផលបរធនបាលកិច្ចសក្តានុពលផ្សេងៗផងដែរ។ កម្មវិធីនេះមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ និងលោកលោកស្រី តំណាងក្រុមហ៊ុនបរធនបាល, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច, ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច, ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងបុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចព្រមទាំងសិក្ខាកាមនៃកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ក្នុងវិស័យបរធនបាលកិច្ច លើកទី៨ ផងដែរ។



**រូបភាព៖** សិក្ខាសាលាស្តីពី "យន្តការបរធនបាលកិច្ចក្នុងបរិការណ៍នៃការវិវត្តថ្មីៗ"។

## កម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៨ ឆ្នាំ២០២៦

នាព្រឹកថ្ងៃសុក្រ ៤ រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានអញ្ជើញចូលរួមកាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៨ ឆ្នាំ២០២៦ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។



**រូបភាព៖** កម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៨ ឆ្នាំ២០២៦។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី"

នាព្រឹកថ្ងៃចន្ទ ៧រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី" សម្រាប់ខេត្ត-ពោធិ៍សាត់ នៅសណ្ឋាគារពោធិ៍សាត់រីវើសាយ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និង **ឯកឧត្តម លឹម សុខតូ អភិបាលរងខេត្តពោធិ៍សាត់** អមដោយ **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 និង **លោក ហៃ ធូរ៉ា ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត-ពោធិ៍សាត់**។ កម្មវិធីនេះ រៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសាវតា និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សមាជិកសហគមន៍កសិកម្ម និងកសិធុរកិច្ចដែលស្ថិតនៅខេត្តពោធិ៍សាត់ ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកអាជីវកម្មរបស់ខ្លួន។

សិក្ខាសាលានេះ មានការចូលរួមដោយតំណាងសមាជិក/សមាជិកាសហគមន៍កសិកម្ម, មន្ត្រី និងទីប្រឹក្សារបស់គម្រោង ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, និងក្រុមការងារគម្រោងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana Bank)។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី"។

## ការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) សម្រាប់ចូលបម្រើការងារនៅ ន.ប.ធ.

នាព្រឹកថ្ងៃចន្ទ ៧រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៦ និយ័តករបេឡាជាតិ (**ន.ប.ធ.**) បានរៀបចំការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) សម្រាប់ចូលបម្រើការងារនៅ **ន.ប.ធ.** នៅមណ្ឌលប្រឡង សាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា ក្រោមអធិបតីភាពរបស់ **លោក យុន វិសនា** អគ្គនាយករងនៃនិយ័តករបេឡាជាតិ (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគណៈកម្មការរៀបចំការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** សម្រាប់ចូលបម្រើការងារនៅ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកាត់វិញ្ញាសា និងប្រកាសបើកការប្រឡង។ មុនពេលចាប់ផ្តើមប្រកាសបើកការប្រឡង លោក-អគ្គនាយករង បានផ្តល់ការណែនាំដល់បេក្ខជន-បេក្ខនារី ដែលបានចូលរួមប្រឡងទាំងអស់ ត្រូវគោរព និងអនុវត្តតាមសេចក្តីណែនាំស្តីពី "ការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) សម្រាប់ចូលបម្រើការងារនៅ **ន.ប.ធ.**" ឱ្យបានម៉ឺងម៉ាត់ និងត្រឹមត្រូវ។

លោកអគ្គនាយករង ក៏បានមានប្រសាសន៍ថា ការប្រឡងប្រជែងនេះគឺជាផ្តល់ឱកាសស្មើៗគ្នាសម្រាប់បេក្ខជន-បេក្ខនារី ទាំងអស់ ដែលឈរលើគោលការណ៍តម្លាភាព និងយុត្តិធម៌។



រូបភាព៖ ការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) សម្រាប់ចូលបម្រើការងារនៅ ន.ប.ធ.។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី"

នាព្រឹកថ្ងៃអង្គារ ៨រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦ និយ័តករបេឡាជាតិ (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី" សម្រាប់ខេត្តកំពង់ឆ្នាំង នៅសណ្ឋាគារសុវណ្ណភូមិ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបេឡាជាតិ និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1, **ឯកឧត្តម ពេជ្រ កែវមុនី** អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និង **លោក ប្រាក់ លាងហ៊ួរ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង** អមដោយ **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 និង **លោក រុន វិសិដ្ឋ តំណាងអង្គភាពគ្រប់គ្រងគម្រោងសមាសភាពទី២ (PIU2)** នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

កម្មវិធីនេះ រៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសារតៈ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សមាជិកសហគមន៍កសិកម្ម និងកសិធុរកិច្ចដែលស្ថិតនៅខេត្តកំពង់ឆ្នាំង

ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកអាជីវកម្មរបស់ខ្លួន។ សិក្ខាសាលានេះ មានការចូលរួមដោយតំណាងសមាជិកសហគមន៍កសិកម្ម, សហគមន៍កសិកម្ម, មន្ត្រីកសិកម្មឃុំ, មន្ត្រី និងទីប្រឹក្សារបស់គម្រោង ACSEP-PIU1, ACSEP-PIU2, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, និងក្រុមការងារគម្រោងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (SPNB)។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី"។

## សិក្ខាសាលាពិគ្រោះយោបល់ស្តីពី "យុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០"

នៅថ្ងៃអង្គារ ៨រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមក្នុងកម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "យុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** នៅសណ្ឋាគារ សុខា ភ្នំពេញ។ សិក្ខាសាលាពិគ្រោះយោបល់នេះ រៀបចំឡើងក្នុងគោលបំណងដើម្បីពិភាក្សាប្រមូលធាតុចូល និងធ្វើការកែសម្រួលចុងក្រោយលើសេចក្តីព្រាងយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ពីក្រសួង-ស្ថាប័នពាក់ព័ន្ធ។



រូបភាព៖ សិក្ខាសាលាពិគ្រោះយោបល់ស្តីពី "យុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០"។

## កិច្ចប្រជុំបច្ចេកទេសជាមួយតំណាងដៃគូ-អភិវឌ្ឍ ពិនិត្យនិងពិភាក្សាលើរបាយការណ៍តាមដាននិងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤

នាព្រឹកថ្ងៃសុក្រ ១១រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេសជាមួយតំណាងដៃគូអភិវឌ្ឍ ពិនិត្យនិងពិភាក្សាលើរបាយការណ៍តាមដាននិងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ដើម្បីត្រៀមលក្ខណៈសម្រាប់កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត យ៉េត វីណែល អនុរដ្ឋលេខាធិការ** នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃ **អ.គ.ហ.** និងមានការអញ្ជើញចូលរួមពីតំណាងដៃគូអភិវឌ្ឍ, ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំបច្ចេកទេសជាមួយតំណាងដៃគូអភិវឌ្ឍ ពិនិត្យនិងពិភាក្សាលើរបាយការណ៍តាមដាននិងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្ដីពី “ការវាយតម្លៃហានិភ័យថ្នាក់ជាតិស្ដីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២”

នាព្រឹកថ្ងៃពុធ ៩កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦, **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច**នៃ **ន.ប.ធ.** បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្ដីពី “ការវាយតម្លៃហានិភ័យថ្នាក់ជាតិស្ដីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវបណ្ឌិត ជា សិរី** អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងជាអនុប្រធានប្រចាំការគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ព្រមទាំងមានការចូលរួមពី **លោកជំទាវ សុខ ឆវ័ន្ត** អនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌និងជាសហប្រធានក្រុមការងារចម្រុះទទួលបន្ទុករៀបចំរបាយការណ៍រួមនៃការវាយតម្លៃហានិភ័យថ្នាក់ជាតិស្ដីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ, **ឯកឧត្តម ហេង បូមករា** ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា, **ឯកឧត្តម Christian- DesRoches** អគ្គរដ្ឋទូតកាណាដាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោកស្រី Tania Meyer ប្រធានគ្រប់គ្រងធនាគារពិភពលោកប្រចាំកម្ពុជា និង ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ប្រព្រឹត្តទៅនៅសណ្ឋាគារហៃយ៉ាត់ រីជិនសុី ភ្នំពេញ។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្ដីពី “ការវាយតម្លៃហានិភ័យថ្នាក់ជាតិស្ដីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២”។

## សិក្ខាសាលាស្ដីពី “ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម ដល់រដ្ឋបាលខេត្តគោលដៅថ្មី”

ចាប់ពីថ្ងៃចន្ទ ៧កើត ដល់ថ្ងៃពុធ ៩កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្ដីពី “ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP” ក្រោមអធិបតីភាពរបស់ **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ**នៃ **ន.ប.ធ.** និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 នៅខេត្តបន្ទាយមានជ័យ។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសារៈតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សហគមន៍កសិកម្ម និងកសិធុរកិច្ច ដល់សមាជិក-សមាជិកាសហគមន៍កសិកម្មចំនួន ៥ រួមមាន៖ សហគមន៍កសិកម្មសាមគ្គីម៉ាឡៃ, សហគមន៍កសិកម្មអូរសំព័រសាមគ្គីស្ម័គ្រចិត្ត, សហគមន៍កសិកម្មមាន់ស្រែចំណោម, សហគមន៍កសិកម្មបន្ទាយនាងមានជ័យ និងសហគមន៍កសិកម្មសាមគ្គីបន្លែឃុំរហាត់ទឹក ខេត្តបន្ទាយមានជ័យ ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកផែនការអាជីវកម្មរបស់ខ្លួន។

សិក្ខាសាលានេះ មានការចូលរួមដោយ សមាជិក/សមាជិកាសហគមន៍កសិកម្ម, មន្ត្រី និងទីប្រឹក្សារបស់ ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបន្ទាយមានជ័យ, និងក្រុមការងារគម្រោងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana Bank)។



រូបភាព៖ សិក្ខាសាលាស្ដីពី “ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម ដល់រដ្ឋបាលខេត្តគោលដៅថ្មី”។

## កិច្ចប្រជុំក្រុមការងារបញ្ញាបយេនឌ័រក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ)

នារសៀលថ្ងៃពុធ ៩កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងជាសមាជិកក្រុមការងារបញ្ញាបយេនឌ័រ** អមដោយសហការី បានចូលរួមកិច្ចប្រជុំក្រុមការងារបញ្ញាបយេនឌ័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**កសហវ**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ កែវ ចរិយា រដ្ឋលេខាធិការ កសហវ និងជាប្រធានក្រុមការងារបញ្ញាបយេនឌ័រ កសហវ** ដោយមានការចូលរួមពី តំណាងនៃគ្រប់អង្គភាពក្រោមឱវាទ **កសហវ** និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

កិច្ចប្រជុំនេះរៀបចំឡើងក្នុងគោលបំណង ដើម្បីពិនិត្យ និងពិភាក្សាលើសមិទ្ធផលការងារឆ្នាំ២០២៥ និងទិសដៅបន្តការងារឆ្នាំ២០២៦។



រូបភាព៖ កិច្ចប្រជុំក្រុមការងារបញ្ញាបយេនឌ័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ)។

## កិច្ចប្រជុំអន្តរក្រសួងស្តីពីការពិនិត្យ និងពិភាក្សាលើ "សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិកីឡាជនពិការ តេជោសែន"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១០កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ស.ព.២៥៦៩ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦ ដោយទទួលបានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច** និងសហការីបានចូលរួមកិច្ចប្រជុំអន្តរក្រសួងស្តីពីការពិនិត្យ និងពិភាក្សាលើ "សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិកីឡាជនពិការ តេជោសែន" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ិន ទីរៈជាតិ រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី** ដោយមានការអញ្ជើញចូលរួមពី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត នៅអគារភោគភាព សាលប្រជុំ ៧-០៨ ជាន់ទី៧ នៃទីស្តីការគណៈរដ្ឋមន្ត្រី។



រូបភាព៖ កិច្ចប្រជុំអន្តរក្រសួងស្តីពីការពិនិត្យ និងពិភាក្សាលើ "សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិកីឡាជនពិការ តេជោសែន"។

## កិច្ចប្រជុំអន្តរក្រសួងស្តីពី "ការពិគ្រោះយោបល់ប្រមូលធាតុចូល លើសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍធុរកិច្ចថ្មី ២០២៦-២០៣០"

នាព្រឹកថ្ងៃពុធ ៩កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក បៀន យាងជូ ប្រធានការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ទីផ្សារ** នៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួងស្តីពី "ការពិគ្រោះយោបល់ប្រមូលធាតុចូល លើសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍធុរកិច្ចថ្មី ២០២៦-២០៣០" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** (**កសហវ**) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ព្រមទាំងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងតំណាងនិយ័តករពាក់ព័ន្ធ នៅសាលប្រជុំអគារ "យ" នៃទីស្តីការ **កសហវ**។



រូបភាព៖ កិច្ចប្រជុំអន្តរក្រសួងស្តីពី "ការពិគ្រោះយោបល់ប្រមូលធាតុចូលលើសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍធុរកិច្ចថ្មី ២០២៦-២០៣០"។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## វេទិកាបណ្ដាញហិរញ្ញវត្ថុ និងបច្ចេកវិទ្យាសកលជប៉ុន ឆ្នាំ២០២៦

ចាប់ពីថ្ងៃអង្គារដល់ថ្ងៃសុក្រ ៨ ដល់ ១១កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៤-២៧ ខែកុម្ភៈ ឆ្នាំ២០២៦ ដោយទទួលបានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ. លោក រិន វដ្ឋា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច, លោក ណាង សេរីវុធ អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** និង **លោក រិទ្ធ គឹមហុង មន្ត្រីនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** បានចូលរួមជាមួយគណៈប្រតិភូកម្ពុជា ដើម្បីចូលរួម "វេទិកាបណ្តាញហិរញ្ញវត្ថុ និងបច្ចេកវិទ្យាសកលជប៉ុន ឆ្នាំ២០២៦ (Global Finance & Technology Network Forum 2026)" នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ក្នុងគោលបំណងដើម្បីសិក្សាឈ្វេងយល់ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យាឌីជីថល, នវានុវត្តន៍សេវាហិរញ្ញវត្ថុ, ទិន្នន័យនិងអភិបាលកិច្ចទិន្នន័យ, បញ្ញាសិប្បនិម្មិតក្នុងហិរញ្ញវត្ថុនិងបច្ចេកវិទ្យា, ទ្រព្យឌីជីថលនិងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ដែលរួមបញ្ចូលនូវការប្រឆាំងការសម្អាតប្រាក់ (AML) និងអនុលោមភាពគតិយុត្ត និងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីនិងនវានុវត្តន៍។







រូបភាព៖ វេទិកាបណ្តាញហិរញ្ញវត្ថុ និងបច្ចេកវិទ្យាសកលជប៉ុន ឆ្នាំ២០២៦។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888